នស/រកម/១០០៥/០២៧

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សម្ពោហរាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបការដាក់គ្រាប់បែកផ្ទុះរបស់ភេរវករ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាប ការដាក់គ្រាប់បែកផ្ទុះរបស់ភេរវករ

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអន្តរជាតិ ស្តីពីការបង្ក្រាបការដាក់គ្រាប់បែកផ្ទុះរបស់ភេរវករ ដែលអនុម័តដោយមហាសន្និបាត អង្គការសហប្រជាជាតិនាសម័យប្រជុំពេញអង្គលើកទី ៧២ នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញា នេះ ។

**មាត្រា ៣.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

៣រល.០៥១០.៤៥៧ ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

សមាជិកនៃអង្គការសហប្រជាជាតិ

ហត្ថលេខា ព្រះហស្តលេខា

ស ខេង នរោត្តម សិរីវុឌ្ឍ

លេខ ... ច.ល

ដើម្បីចម្លងចេញ

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ម៉ានិត

សេចក្តីសំរេចអនុមត័ដោយមហាសន្និបាត

( របាយការណ៍របស់គណកម្មាធិការទី ៦ ( អា/៥២/៦៥៣) )

៥២/១៦៤. អនុសញ្ញាអន្តរជាតិស្តីអំពីការបង្ក្រាបការដាក់ជាតិផ្ទុះរបស់ភេរវករ

*មហាសន្និបាទ*

រំលឹកឡើងវិញនូវសេចក្តីសំរេចរបស់ខ្លួន ៤៩/៦០ ថ្ងៃទី ៩ ខែ ធ្នូ ១៩៩៤ ដែលខ្លួនបានអនុម័តលើសេចក្តីប្រកាសស្តីអំពីវិធានការលុបបំបាត់អំពើភេរវកម្មអន្តរជាតិ និង សេចក្តីសំរេចរបស់ខ្លួន ៥១/២១០ ចុះថ្ងៃទី ១៧ ខែ ធ្នូ ១៩៩៦ ។

ដោយបានពិចារណាលើឯកសារពង្រាងអនុសញ្ញាក្នុងការបង្ក្រាបលើការដាក់ជាតិផ្ទុះរបស់ភេរវករ ដែលរៀបចំដោយគណកម្មាធិការពិសេសរបស់ខ្លួនដែលបង្កើតឡើងដោយសេចក្តីសំរេចរបស់មហាសន្និបាត ៥១/២១០ ចុះថ្ងៃទី ១៧ ធ្នូ ១៩៩៦ និង ក្រុមការងាររបស់គណកម្មាធិការទីប្រាំមួយ[១] ៖

១. អនុម័តអនុសញ្ញាអន្តរជាតិស្តីអំពីការបង្ក្រាបការដាក់គ្រាប់បែកផ្ទុះភ្ជាប់ទៅនឹងសេចក្តីសំរេចបច្ចុប្បន្ន និង សំរេចបើកចំហរសំរាប់ការចុះហត្ថលេខានៅទីស្នាក់ការរបស់អង្គការសហប្រជាជាតិនៅ ញូយក ចាប់ពីថ្ងៃទី ១២ ខែ មករា ១៩៩៨ ដល់ ៣១ ធ្នូ ១៩៩៩ ។

២. ស្នើរសុំដល់រដ្ឋទាំងអស់ចុះហត្ថលេខា និង ធ្វើសច្ចាប័ន ទទួលយក ឬ ឯកភាព ឬដាក់បន្ថែមទៅនឹងអនុសញ្ញា ។

កិច្ចប្រជុំសាធារណទី ៧២

១៥ ធ្នូ ១៩៩៧

[1] See Official Records of the General Assembly, Fifty-second Session, Supplement No. 37 (A/52/37).

ឧបសម្ព័ន្ធ

អនុសញ្ញាអន្តរជាតិស្តីអំពីការបង្ក្រាបការដាក់

គ្រាប់បែកផ្ទុះរបស់ភេរវករ

ភាគីរដ្ឋក្នុងអនុសញ្ញានេះ

បានយល់ឃើញពីគោលបំណង និង គោលការណ៍អំពីរដ្ឋធម្មនុញ្ញរបស់អង្គការសហប្រជាជាតិទាក់ទងនឹងការថែរក្សាសន្តិភាពអន្តរជាតិ និង សន្តិសុខ និង ការបង្កើនទំនាក់ទំនងក្នុងភាពជាអ្នកជិតខាងល្អ និង ជាមិត្តភាព និង កិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋ ។

ដោយមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីការកើនឡើងនូវសកម្មភាពភេរវកម្មគ្រប់ទំរង់ និង គ្រប់រូបភាព ។

ដោយរំលឹកឡើងវិញលើសេចក្តីប្រកាសក្នុងឱកាសខួបលើកទី ៥០ របស់អង្គការសហប្រជាជាតិ នៅថ្ងៃទី ២៤ ខែ តុលា ១៩៩៥ ។[២]

ដោយរំលឹកឡើងវិញផងដែរលើសេចក្តីប្រកាសស្តីអំពីវិធានការដើម្បីលុបបំបាត់អំពើភេរវកម្មអន្តរជាតិ ដោយភ្ជាប់ទៅនឹងសេចក្តីសំរេចរបស់មហាសន្និបាត ៤៩/៦០ ចុះថ្ងៃទី ៩ ខែ ធ្នូ ១៩៩៤ ដែលក្នុងនោះ "រដ្ឋសមាជិករបស់អង្គការសហប្រជាជាតិបានបញ្ជាក់យ៉ាងឱឡារិកនូវការថ្កោលទោសជាឯកច្ឆន្ទរាល់អំពើ វិធីសាស្ត្រ និង ការប្រព្រឹត្តិរបស់ភេរវករថាជាជនល្មើស និង គ្មានហេតុផល ទោះធ្វើឡើងនៅទីកន្លែងណា ឬ ដោយអ្នកណាក៏ដោយរួមទាំងអ្វីៗដែលធ្វើអោយរាំងស្ទះដល់ទំនាក់ទំនងជាមិត្តភាពក្នុងបណ្តារដ្ឋ និង ប្រជាជន និង គំរាមកំហែងដល់បូរណភាពដែនដី និង សន្តិសុខរបស់រដ្ឋ" ។

ដោយកត់សំគាល់ឃើញថាសេចក្តីប្រកាសក៏បានលើកទឹកចិត្តដល់រដ្ឋ "អោយធ្វើការពិនិត្យឡើងវិញជាបន្ទាន់លើវិសាលភាពនៃបញ្ញត្តិច្បាប់អន្តរជាតិដែលមានចែងអំពីការបង្ការទុបស្កាត់ ការបង្ក្រាប និង ការលុបបំបាត់

[2] See resolution 50/6

អំពើភេរវកម្មគ្រប់រូបភាពសំដៅកំណត់អោយបានថាមានគោលការច្បាប់ដ៏ទូលំលាយមួយដែលលើកឡើងរាល់ចំនុចនានាដែលទាក់ទងនឹងបញ្ហានេះ ។

ដោយរំលឹកឡើងវិញអំពីសេចក្តីសំរេច ៥១/២១០ ចុះថ្ងៃទី ១៧ ខែ ធ្នូ ១៩៩៦ និង សេចក្តីប្រកាសបន្ថែម គឺសេចក្តីប្រកាស ១៩៩៤ ស្តីអំពីវិធានការដើម្បីលុបបំបាត់អំពើភេរវកម្មដែលតទៅភ្ជាប់នឹងឧបសម្ពន្ធ័នេះ ។

ដោយកត់សំគាល់ឃើញថាការវាយប្រហាររបស់ភេរវករដោយមធ្យោបាយដាក់ជាតិផ្ទុះ ឬ ឧបករណ៍ដែលមានគ្រោះថ្នាក់ដល់ជីវិតផ្សេងៗទៀតបានកើនឡើងយ៉ាងឆាប់រហ័ស ។

ដោយកត់សំគាល់ឃើញផងដែរថាបញ្ញត្តិច្បាប់ពហុភាគីដែលមានរួចហើយមិនបានលើកឡើងអំពីការវាយប្រហារទាំងនេះអោយបានសមស្រប ។

ដោយមានជំនឿថាត្រូវការបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាបន្ទាន់រវាងរដ្ឋក្នុងការរៀបចំឡើង និងអនុម័តយកវិធានការដែលមានប្រសិទ្ធិភាពក្នុងការទប់ស្កាត់បង្ការអំពើភេរវកម្មទាំងនេះ និង ដើម្បីធ្វើការកាត់ទោស និង ផ្តន្ទាទោសជនល្មើស ។

ដោយយល់ឃើញថាការកើតឡើងនូវអំពើទាំងនេះគឺជាការព្រួយបារម្ភយ៉ាងខ្លាំងរបស់សហគមអន្តរជាតិទាំងមូល ។

ដោយកត់សំគាល់ឃើញថាសកម្មភាពរបស់កំលាំងយោធារបស់រដ្ឋត្រូវគ្រប់គ្រងដោយក្រមច្បាប់អន្តរជាតិខាងក្រៅពីគោលការណ៍របស់អនុសញ្ញានេះ និង ថាការមិនដាក់បញ្ចូលនូវវិធានការមួយចំនួនក្នុងអនុសញ្ញានេះមិនអត់អោន ឬ ធ្វើអោយស្របច្បាប់នូវអំពើណាមួយដែលខុសនឹងច្បាប់ ឬ បង្អាក់ការចោទប្រកាន់ក្រោមច្បាប់ដ៏ទៃៗទៀត ។

*បានព្រមព្រៀងដូចតទៅ:*

មាត្រា ១

ដើម្បីគោលបំណងនៃអនុសញ្ញានេះ:

១. "ឧបករណ៍រដ្ឋាភិបាល ឬ ឧបករណ៍រដ្ឋ" រួមទាំងឧបករណ៍បន្ទោះអាសន្ន ឬ អចិន្ត្រៃយ៍ ឬ គ្រឿងដឹកនាំ ដែលប្រើ ឬ កាន់កាប់ដោយតំណាងរបស់រដ្ឋមួយ ដោយសមាជិករបស់រដ្ឋាភិបាល និតិបញ្ញត្តិ ឬ តុលាការ ឬ ដោយ មន្ត្រី ឬ និយោជិករបស់រដ្ឋមួយ ឬ សមត្ថកិច្ចសាធារណៈផ្សេងៗ ឬ អង្គភាព ឬ ដោយនិយោជិត ឬ មន្ត្រីរបស់អង្គការអន្តរជាតិទាក់ទងនឹងភារៈកិច្ចជាផ្លូវការរបស់ពួកគេ ។

២. "ឧបករណ៍ហេដ្ឋារចនាសម្ព័ន្ធ" មានន័យថារាល់ឧបករណ៍ដែលជាកម្មសិទ្ធិរបស់ឯកជន ឬ សាធារណៈ ដែលផ្តល់ ឬ បែងចែកសេវាសំរាប់ជាផលប្រយោជន៍សាធារណៈ ដូចជាទឹក ប្រពន្ធ័លូទឹកស្អុយ ថាមពល ប្រេង ឬ ទំនាក់ទំនង ។

៣. "ឧបករណ៍ផ្ទុះ ឬ គ្រោះថ្នាក់ដល់ជីវិត" មានន័យថា:

(ក) អាវុធផ្ទុះ ឬ អាវុធដែលបង្កគ្រោះថ្នាក់ ឬ ឧបករណ៍ដែលរៀបចំធ្វើឡើង ឬ មានសមត្ថភាពបង្កអោយស្លាប់ អោយទទួលរងរបួសលើរាងកាយយ៉ាងខ្លាំង ឬ ធ្វើអោយមានការប៉ះពាល់ខូចខាតខ្លាំង ឬ

(ខ) អាវុធ ឬ ឧបករណ៍ដែលរៀបចំធ្វើឡើង ឬ មានលទ្ធភាពបណ្តាលអោយស្លាប់ ធ្វើអោយរងរបួសធ្ងន់ធ្ងរ ឬ ធ្វើអោយខូចខាតទ្រព្យសម្បត្តិធ្ងន់ធ្ងរតាមរយៈការបញ្ចេញ ការចែកចាយ ឬ ការប៉ះពាល់សារធាតុគីមីពុល ភ្នាក់ងារសេរីរាង្គ ឬ ភ្នាក់ងារបំពុល ឬ សារធាតុដូចគ្នា ឬ ឧបករណ៍វិទ្យុសកម្ម និង ព្យុះសកម្ម ។

៤. "កងកំលាំងយោធារបស់រដ្ឋមួយ " មានន័យថាកងកំលាំងប្រដាប់អាវុធរបស់រដ្ឋមួយដែលបានរៀបចំហ្វឹកហ្វឺន

នឹងបំពាក់អាវុធតាមច្បាប់ខាងក្នុងស្រុករបស់ខ្លួនដើម្បីបំរើគោលបំណងសំខាន់មួយនៃការការពារជាតិ ឬ សន្តិសុខ និង បុគ្គលដែលធ្វើសកម្មភាពដើម្បីគាំទ្រកងកំលាំងប្រដាប់អាវុធទាំងនោះ ដែលស្ថិតនៅក្រោមការបញ្ជារបស់ពួកគេ ការគ្រប់គ្រង និង ការទទួលខុសត្រូវ ។

៥. "ទីកន្លែងនៃការប្រើប្រាស់ជាសាធារណៈ" មានន័យថារាល់ផ្នែកទាំងឡាយរបស់អាគារ ដី ផ្លូវថ្នល់ ផ្លូវទឹក ឬ ទីតាំងផ្សេងៗទៀតដែលអាចចូលបាន ឬ បើកចំហរចំពោះសមាជិកសាធារណៈ ទោះបីជា

ប្រចាំ ឬ ម្ដងម្កាល ឬ មួយរយៈ និង រួមមានទីតាំងធ្វើពាណិជ្ជកម្ម ធ្វើជំនួញ វប្បធម៌ ប្រវត្តិសាស្ត្រ អប់រំ សាសនា រដ្ឋាភិបាល កន្លែងកំសាន្តសប្បាយ លំហែកាយ ឬ ទីតាំងដូចគ្នាដែលអាចចូលបាន ឬ បើកចំហរដល់សាធារណៈ ។

៦. "ប្រព័ន្ធដឹកជញ្ជូនសាធារណៈ "មានន័យថារាល់ឧបករណ៍ គ្រឿងមធ្យោបាយដឹកនាំ និងឧបករណ៍ផ្សេងៗទៀតទោះបីជាកម្មសិទ្ធិឯកជន ឬ សាធារណៈដែលត្រូវប្រើប្រាស់ក្នុង ឬ សំរាប់សេវាដែលមានជាសាធារណៈសំរាប់ការដឹកជញ្ជូនមនុស្ស ឬ ទំនិញ ។

## មាត្រា ២

១. ជនណាមួយប្រព្រឹត្តបទល្មើសមួយដែលមានចែងក្នុងអត្ថន័យនៃអនុសញ្ញានេះប្រសិនបើជននោះ ដោយខុសនឹងច្បាប់ និង ដោយចេតនាបញ្ជូន ដាក់ បញ្ចេញ ឬ ដាក់អោយផ្ទុះនូវគ្រាប់ផ្ទុះ ឬ ឧបករណ៍ ដែលមានគ្រោះថ្នាក់ដល់ជីវិតផ្សេងៗទៀត ក្នុង ឬ ចូលទៅក្នុង ឬ ប្រឆាំងនឹងទីកន្លែងមួយដែលសំរាប់ ប្រើប្រាស់ជាសាធារណៈ រដ្ឋមួយ ឬ ឧបករណ៍រដ្ឋាភិបាល ឬ ប្រព័ន្ធដឹកជញ្ជូនសាធារណៈ ឬ ឧបករណ៍ ហេដ្ឋារចនាសម្ព័ន្ធ:

(ក) ដោយចេតនាបណ្ដាលអោយមានការស្លាប់បាត់បង់ជីវិត ឬ គ្រោះថ្នាក់ធ្ងន់ធ្ងរដល់រាងកាយ ឬ

(ខ) ដោយចេតនាបណ្ដាលអោយមានការខូចខាតធ្ងន់ធ្ងរលើកន្លែងទាំងនោះ ឧបករណ៍ ឬ ប្រព័ន្ធ ដែលការបំផ្លាញទាំងនោះបណ្ដាលអោយ ឬ នាំអោយមានការខាតបង់ផ្នែកសេដ្ឋកិច្ចធ្ងន់ធ្ងរ ។

២.ជនណាក៏ដោយក៏ប្រព្រឹត្តបទល្មើសមួយប្រសិនបើជននោះប៉ុនប៉ងប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ។

៣.ជនណាក៏ដោយក៏ប្រព្រឹត្តបទល្មើសមួយប្រសិនបើជននោះ:

(ក) ចូលរួមជាអ្នកសមគំនិតក្នុងបទល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌ ១ ឬ ២ នៃមាត្រានេះ ឬ

(ខ) រៀបចំ ដឹកនាំអ្នកផ្សេងៗទៀតដើម្បីប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខណ្ឌ ១ ឬ ២ នៃមាត្រានេះ ឬ

(គ) តាមមធ្យោបាយណាមួយជួយសំរួលដល់ការប្រព្រឹត្តបទល្មើសមួយ ឬ ច្រើនដូចមានចែងក្នុងកថាខណ្ឌ ១ ឬ ២ នៃមាត្រានេះដោយមនុស្សមួយក្រុមដែលធ្វើសកម្មភាពឡើងជាមួយនឹងគោលបំណង

ឯកភាពគ្នាមួយ ការជួយសំរួលទាំងនោះត្រូវអមដោយចេតនា ហើយអាចធ្វើឡើងដោយមានគោលដៅបង្កើនសកម្មភាព ឬ គោលបំណងព្រហ្មទណ្ឌជាទូទៅរបស់ក្រុម ឬ ធ្វើឡើងដោយដឹងនូវចេតនារបស់ក្រុមដើម្បីប្រព្រឹត្តបទល្មើសមួយ ឬ ច្រើនដែលពាក់ព័ន្ធ ។

មាត្រា ៣

អនុសញ្ញានេះមិនត្រូវយកទៅអនុវត្តចំពោះបទល្មើសដែលប្រព្រឹត្តឡើងនៅក្នុងរដ្ឋមួយ ជនសង្ស័យ និងជនរងគ្រោះគឺជាសញ្ជាតិរបស់រដ្ឋនោះ ជនសង្ស័យត្រូវបានគេរកឃើញក្នុងដែនដីរបស់រដ្ឋនោះ ហើយមិនមានរដ្ឋផ្សេងទៀតមានមូលដ្ឋានណាមួយតាមមាត្រា ៦ កថាខណ្ឌ ១ ឬ កថាខណ្ឌ ២ នៃអនុសញ្ញានេះប្រើប្រាស់ដែនអំណាច លើកលែងតែ បញ្ញត្តិនៃមាត្រា ១០ ដល់ ១៥ ត្រូវប្រើប្រាស់ក្នុងករណីទាំងនោះតាមលក្ខណៈជាក់ស្តែង ។

មាត្រា ៤

ភាគីរដ្ឋនីមួយត្រូវអនុម័តវិធានការដូចនេះតាមការចាំបាច់:

(ក) ដើម្បីកំណត់ថាជាបទល្មើសឧក្រិដ្ឋក្រោមច្បាប់ក្នុងស្រុករបស់ខ្លួននូវបទល្មើសដែលមានចែងក្នុងមាត្រា ២ នៃអនុសញ្ញានេះ

(ខ) កំណត់អោយបទល្មើសទាំងនេះអាចដាក់ទោសបានសមស្របអាស្រ័យទៅតាមភាពធ្ងន់ធ្ងរនៃបទល្មើស ។

មាត្រា ៥

ភាគីរដ្ឋនីមួយៗត្រូវអនុម័តវិធានការចាំបាច់រួមទាំងច្បាប់ក្នុងស្រុកក្នុងករណីសមស្រប ដើម្បីកំណត់ថាជនល្មើសប្រព្រឹត្តអំពើក្នុងវិសាលភាពនៃអនុសញ្ញា ជាពិសេសក្នុងករណីធ្វើឡើងដោយចេតនា ឬ ដោយគិតគូរជាមុនដើម្បីបង្កអោយមានសភាពវិករក្នុងចំណោមសាធារណៈជនទូទៅ ឬ ក្នុងក្រុមមនុស្ស ឬ មនុស្សណាម្នាក់មិនត្រូវបានចាត់ទុកថាមានហេតុផលនោះទេ ក្នុងកាលទេសណាក៏ដោយ ទោះតាមរយៈនយោបាយទស្សនៈវិទ្យា មនោគមវិជ្ជា ពូជសាសន៍ សាសនា ឬ លក្ខណៈផ្សេងៗទៀតស្រដៀងគ្នា និងត្រូវផ្តន្ទាទោសដោយក៏រិត ទោសស្របទៅតាមសភាពធ្ងន់ធ្ងរ ។

មាត្រា ៦

១. ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានការទាំងនេះទៅតាមការចាំបាច់ដើម្បីកំណត់ពីសមត្ថកិច្ចរបស់ខ្លួនលើបទល្មើសដែលមានចែងក្នុងមាត្រា ២ នៅពេលៈ

(ក) បទល្មើសប្រព្រឹត្តឡើងក្នុងដែនដីរបស់រដ្ឋនោះ ឬ

(ខ) បទល្មើសប្រព្រឹត្តឡើងលើនាវាដែលបង្ហោះទង់ជាតិរបស់រដ្ឋនោះ ឬ អាកាសយាន្តដែលបានចុះបញ្ជីក្រោមច្បាប់របស់រដ្ឋនោះនៅពេលដែលបទល្មើសនោះបានប្រព្រឹត្តឡើង ឬ

(គ) បទល្មើសប្រព្រឹត្តឡើងដោយសញ្ជាតិរបស់រដ្ឋនោះ ។

២. ភាគីរដ្ឋមួយក៏អាចកំណត់ពីដែនសមត្ថកិច្ចរបស់ខ្លួនលើបទល្មើសទាំងនោះនៅពេលដែលៈ

(ក) បទល្មើសប្រព្រឹត្តឡើងប្រឆាំងនឹងសញ្ជាតិរបស់រដ្ឋនោះ ឬ

(ខ) បទល្មើសប្រព្រឹត្តឡើងប្រឆាំងនឹងរដ្ឋមួយ ឬ ឧបករណ៍រដ្ឋាភិបាលរបស់រដ្ឋនោះនៅក្រៅប្រទេសរួមទាំងស្ថានទូត ឬ ទីតាំងការទូត ឬ កុងសុលផ្សេងរបស់រដ្ឋនោះ ឬ

(គ) បទល្មើសប្រព្រឹត្តឡើងដោយជនដែលគ្មានរដ្ឋ តែមានទីស្នាក់អាស្រ័យរបស់ខ្លួននៅក្នុងដែនដីរបស់រដ្ឋនោះ ឬ

(ឃ) បទល្មើសប្រព្រឹត្តឡើងក្នុងគោលបំណងបង្ខិតបង្ខំរដ្ឋនោះអោយធ្វើ ឬ ដកថយពីការធ្វើអំពើទាំងឡាយនោះ ឬ

(ង) បទល្មើសប្រព្រឹត្តឡើងលើយានអវកាសដែលប្រតិបត្តិការដោយរដ្ឋាភិបាលរបស់រដ្ឋនោះ ។

៣. បន្ទាប់ពីការធ្វើសច្ចាប័ន ការទទួលយក ការឯកភាព និង ការដាក់ប្រើប្រាស់បន្ថែមលើអនុសញ្ញានេះ ភាគីរដ្ឋនីមួយៗត្រូវជូនដំណឹងដល់អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិនូវដែនអំណាចដែលខ្លួនបានកំណត់ក្រោមច្បាប់ក្នុងស្រុករបស់ខ្លួនស្របតាមកថាខណ្ឌ ២ នៃមាត្រានេះ ។ ប្រសិនបើមានការផ្លាស់ប្តូរអ្វី ភាគី រដ្ឋដែលពាក់ពន្ធ័ត្រូវជូនដំណឹងជាបន្ទាន់ដល់អគ្គលេខាធិការ ។

៤. ភាគីរដ្ឋនីមួយៗក៏ត្រូវចាត់វិធានការទាំងនេះតាមការចាំបាច់ដើម្បីកំណត់អំពីដែនសមត្ថកិច្ចរបស់ខ្លួនលើបទល្មើសដែលមានចែងក្នុងមាត្រា ២ ក្នុងករណីដែលជនល្មើសមានវត្តមានក្នុងដែនដីរបស់ខ្លួនហើយខ្លួនមិនធ្វើបត្យាប័នជននោះទៅបណ្តាភាគីរដ្ឋផ្សេងៗទៀតដែលបានកំណត់ដែនសមត្ថកិច្ចរបស់ពួកគេស្របតាមកថាខណ្ឌ ១ ឬ ២ នៃមាត្រានេះ ។

៥. អនុសញ្ញានេះមិនរំលាយចោលរាល់ដែនសមត្ថកិច្ចទាំងឡាយណាដែលភាគីរដ្ឋបង្កើតឡើងស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួននោះទេ ។

## មាត្រា ៧

១. បន្ទាប់ពីបានទទួលពត៌មានថាជនណាម្នាក់ដែលបានប្រព្រឹត្តបទល្មើស ឬ ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសមួយដូចមានចែងក្នុងមាត្រា ២ មានវត្តមានក្នុងដែនដីរបស់ខ្លួន ភាគីរដ្ឋដែលពាក់ពន្ធ័ត្រូវចាត់វិធានការទាំងនោះតាមការចាំបាច់ក្រោមច្បាប់ក្នុងស្រុករបស់ខ្លួនដើម្បីស៊ើបអង្កេតអង្គហេតុដែលមាននៅក្នុងពត៌មាននោះ ។

២. នៅពេលដែលបំពេញតំរូវការគ្រប់គ្រាន់ក្នុងការទទួលបានដីកា ភាគីរដ្ឋដែលក្នុងដែនដីរបស់ខ្លួនមានវត្តមានជនល្មើស ឬ ជនជាប់ចោទត្រូវចាត់វិធានការសមស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួនដើម្បីកំណត់អោយច្បាស់នូវវត្តមានរបស់ជននោះសំរាប់ការកាត់ទោស ឬ ការធ្វើបត្យាប័ន ។

៣. ជនទាំងឡាយណាដែលត្រូវបានគេចាត់វិធានការដូចក្នុងកថាខណ្ឌ ២ នៃមាត្រានេះត្រូវមានសិទ្ធិ:

(ក) ទំនាក់ទំនងដោយមិនបង្អង់ជាមួយនឹងតំណាងដែលនៅជិតបំផុតរបស់រដ្ឋរបស់ជននោះ ឬ បើពុំនោះទេត្រូវបានទទួលការការពារសិទ្ធិរបស់ជននោះ ឬ ប្រសិនបើជននោះមិនមានប្រទេស គឺដោយរដ្ឋដែលជននោះស្នាក់នៅ ។

(ខ) ទទួលការសួរសុខទុក្ខដោយតំណាងរបស់រដ្ឋនោះ ។

(គ) ទទួលការជូនដំណឹងអំពីសិទ្ធិរបស់ជននោះតាមកថាខណ្ឌ (ក) និង (ខ)

៤. សិទ្ធិដែលមានចែងក្នុងកថាខណ្ឌ ៣ នៃមាត្រានេះត្រូវអនុវត្តដោយស្របទៅតាមច្បាប់ និងគោលការណ៍របស់រដ្ឋដែលដែនដីរបស់រដ្ឋនោះមានវត្តមានជនល្មើស ឬ ជនដែលជាប់ចោទក្នុង ករណីដែលបញ្ញត្តិ នៃច្បាប់នោះ និង គោលការណ៍ផ្តល់សុពលភាពពេញលេញទៅតាមគោលបំណងនៃការផ្តល់សិទ្ធិដែលមាន ចែងក្នុងកថាខណ្ឌ ៣ ។

៥. បញ្ញត្តិនៃកថាខណ្ឌ ៣ និង ៤ នៃមាត្រានេះមិនត្រូវរើសអើងចំពោះសិទ្ធិរបស់ភាគីរដ្ឋដែលទាមទារនូវដែនសមត្ថកិច្ចស្របតាមមាត្រា ៦ អនុកថាខណ្ឌ ១(គ) និង ២(គ) ដើម្បីអញ្ជើញគណកម្មាធិការអន្តរជាតិរបស់អង្គការកាកបាទក្រហមអោយទំនាក់ទំនង និង ចូលសួរសុខទុកជនល្មើសដែលជាប់ចោទនោះ ។

៦. ស្របតាមមាត្រានេះ នៅពេលដែលភាគីរដ្ឋមួយបានបង្ខាំងអ្នកណាម្នាក់ ខ្លួនត្រូវជូនដំណឹងជាបន្ទាន់ ដោយផ្ទាល់ ឬ តាមរយៈអគ្គលេខារបស់អង្គការសហប្រជាជាតិ ភាគីរដ្ឋដែលបានកំណត់ដែនសមត្ថកិច្ចស្របតាមមាត្រា ៦ កថាខណ្ឌ ១ និង ២ និង ប្រសិនបើខ្លួនគិតថាសមស្រប ភាគីរដ្ឋផ្សេងៗទៀតៗដែលពាក់ព័ន្ធ លើការដែលជននោះត្រូវឃុំខ្លួន និង ក្នុងស្ថានភាពដែលទាមទារអោយមានការឃុំខ្លួនជននោះ ។ រដ្ឋដែលធ្វើការស៊ើបអង្កេតដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះត្រូវជូនដំណឹងភ្លាមដល់បណ្តាភាគីរដ្ឋដូចបានលើកឡើងខាងលើនូវការរកឃើញរបស់ខ្លួន និង ត្រូវបង្ហាញថាតើខ្លួនមានបំណងប្រើប្រាស់ដែនសមត្ថកិច្ចរបស់ខ្លួន ឬ អត់ ។

មាត្រា ៨

១. ភាគីរដ្ឋដែលមានវត្តមានរបស់ជនជាប់ចោទក្នុងដែនដីរបស់ខ្លួន ក្នុងករណីដែលអនុវត្តមាត្រា៦ ហើយប្រសិនបើខ្លួនមិនធ្វើបត្យាប័នជននោះ ត្រូវមានកាតព្វកិច្ច ដោយគ្មានករណីលើកលែងអ្វីទាំងអស់ ទោះជាជនល្មើសនោះប្រព្រឹត្ត ឬ មិនប្រព្រឹត្តក្នុងដែនដីរបស់ខ្លួន បញ្ជូនករណីនោះដោយមិនបង្អង់ទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីធ្វើការចោទប្រកាន់ តាមរយៈនិតិវិធីស្របតាមច្បាប់របស់រដ្ឋនោះ ។ អាជ្ញាធរទាំងនោះធ្វើសេចក្តីសំរេចរបស់ខ្លួនតាមវិធីដូចគ្នាដូចក្នុងករណីបទល្មើសផ្សេងៗទៀតដែលមានសភាពធ្ងន់ធ្ងរ តាមច្បាប់របស់រដ្ឋនោះ ។

២. ក្នុងករណីដែលភាគីរដ្ឋត្រូវបានទទួលការអនុញ្ញាតិពីច្បាប់ក្នុងស្រុករបស់ខ្លួនអោយធ្វើបត្យាប័ន ឬ បើពុំនោះទេបញ្ជូនជនជាតិរបស់ខ្លួនតាមលក្ខខណ្ឌដែលថាជននោះនឹងត្រូវបញ្ជូនទៅរដ្ឋនោះដើម្បីបំរើទោសដែលបានដាក់ដោយសារជាលទ្ធផលនៃសវនាការ ឬ ដំណើរនិតិវិធីដែលនៃការធ្វើបត្យាប័ន និង ការបញ្ជូនជនជាតិរបស់ខ្លួន ហើយរដ្ឋនេះ និង រដ្ឋដែលស្នើសុំការធ្វើបត្យាប័នលើជននោះឯកភាពលើយោបល់នេះ និង លក្ខខណ្ឌដែលពួកគេគិតថាសមស្រប ការធ្វើបត្យាប័នក្រោមលក្ខណ្ឌទាំងនោះត្រូវគ្រប់គ្រាន់ដើម្បីអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ។

មាត្រា ៩

១. បទល្មើសដែលមានចែងក្នុងមាត្រា ២ ត្រូវយល់ថាមានការរួមបញ្ចូលថាជាបទល្មើសដែលអាចដែលអាចធ្វើបត្យាប័នបានក្នុងសន្ធិសញ្ញាបត្យាប័នណាក៏ដោយដែលមានរវាងភាគីរដ្ឋនានាមុនពេលចូលជា

ធរ មាននៃអនុសញ្ញានេះ ។ ភាគីរដ្ឋរួមបញ្ចូលបទល្មើសទាំងនេះថាជាបទល្មើសដែលអាចធ្វើបត្យាប័នបាន នៅគ្រប់សន្ធិសញ្ញាដែលត្រូវធ្វើឡើងក្រោយៗមកទៀតរវាងពួកគេ ។

២. នៅពេលដែលភាគរដ្ឋដែលធ្វើបត្យាប័នដោយមានលក្ខណ្ឌតាមអត្ថិភាពនៃសន្ធិសញ្ញាមួយ ទទួលសំណើរស្នើសុំការធ្វើបត្យាប័នពីភាគីរដ្ឋផ្សេងមួយទៀតដែលមិនមានសន្ធិសញ្ញាធ្វើបត្យាប័នជាមួយរដ្ឋដែលត្រូវគេស្នើសុំអាច តាមជំរើសរបស់ខ្លួន ចាត់ទុកអនុសញ្ញានេះជាមូលដ្ឋានច្បាប់សំរាប់ការធ្វើបត្យាប័នលើបទល្មើសដែលមានចែងក្នុងមាត្រា ២ ។ ការធ្វើបត្យាប័នត្រូវផ្អែកលើលក្ខណ្ឌផ្សេងដែលមានចែងក្នុងច្បាប់របស់រដ្ឋទទួលសំណើរ ។

៣. ភាគីរដ្ឋដែលមិនធ្វើបត្យាប័ដោយលក្ខខណ្ឌលើអត្ថិភាពនៃសន្ធិសញ្ញាត្រូវទទួលស្គាល់បទល្មើសដែលមានចែងក្នុងមាត្រា ២ ថាជាបទល្មើសដែលអាចធ្វើបត្យាប័នបានរវាងពួកផងខ្លួន អាស្រ័យទៅតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់របស់រដ្ឋទទួលសំណើរ ។

៤. ប្រសិនបើចាំបាច់ បទល្មើសដែលមានចែងក្នុងមាត្រា ២ ក្នុងគោលបំណងនៃការការធ្វើបត្យាប័នរវាងភាគីត្រូវគិតថាដូចក្នុងករណីដែលបទល្មើសប្រព្រឹត្តឡើងមិនត្រឹមតែក្នុងកន្លែងណាមួយដែលបទល្មើសនោះកើតឡើងនោះទេ កំប៉ុន្តែក្នុងដែនដីរបស់រដ្ឋដែលបានកំណត់ដែនសមត្ថកិច្ចស្របតាមមាត្រា ៦ កថាខណ្ឌ ១ និង ២ ។

៥. បញ្ញត្តិនៃសន្ធិសញ្ញាបត្យាប័នទាំងអស់ និង ការឯកភាពផ្សេងៗរវាងភាគីរដ្ឋទាក់ទងនឹងបទល្មើសដែលមានចែងក្នុងមាត្រា ២ ត្រូវយល់ថាអាចធ្វើការកែតំរូវបានរវាងភាគីរដ្ឋអាស្រ័យដោយភាពស្របគ្នាជាមួយនឹងអនុសញ្ញានេះ ។

## មាត្រា ១០

១. ភាគីរដ្ឋត្រូវសំរបសំរួលជួយគ្នាអោយអស់ពីសមត្ថភាពទាក់ទងនឹងការស៊ើបអង្កេត ឬ ដំណើរការ និងនិតិវិធីធ្វើបត្យាប័នដែលមានលើបទល្មើសដូចមានចែងក្នុងមាត្រា ២ ដោយរួមបញ្ចូលទាំងការជួយក្នុងការទទួលបានភស្តុតាងផ្សេងតាមតំរូវការចាំបាច់របស់និតិវិធី ។

២. ភាគីរដ្ឋត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកថាខណ្ឌ ១ នៃមាត្រានេះដោយស្របតាមរាល់សន្ធិសញ្ញា ឬ ការឯកភាពផ្សេងៗលើការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ដែលអាចមានរវាងពួកគេ ។ ក្នុង

ករណីមិនមានសន្ធិសញ្ញា ឬ ការរៀបចំទាំងនោះ ភាគីរដ្ឋត្រូវជួយគ្នាទៅវិញទៅមកស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួន ។

មាត្រា ១១

ដើម្បីគោលបំណងនៃការធ្វើបត្យាប័ន ឬ ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ មិនមានបទល្មើសមួយណាដែលចែងក្នុងមាត្រា ២ត្រូវចាត់ទុកថាជាបទល្មើសនយោបាយ ឬ ជាបទល្មើសដែលទាក់ទងនឹងបទល្មើសនយោបាយ ឬ ជាបទល្មើសដែលប្រព្រឹត្តឡើងដើម្បីហេតុផលនយោបាយនោះទេ ។ ជាមួយគ្នានេះដែរ សំណើរសុំការធ្វើបត្យាប័ន ឬ ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ដែលផ្អែកលើបទល្មើសដូចនេះអាចមិនត្រូវបានបដិសេធដោយសារតែមូលហេតុមួយថា វាពាក់ព័ន្ធនឹងបទល្មើសនយោបាយមួយ ឬ បទល្មើសដែលពាក់ព័ន្ធនឹងបទល្មើសនយោបាយ ឬ បទល្មើសដែលមានចេតនានយោបាយ ។

មាត្រា ១២

មិនមានអ្វីនៅក្នុងអនុសញ្ញានេះដែលត្រូវបកស្រាយថាជាការដាក់បង្ខំកាតព្វកិច្ចដើម្បីអោយធ្វើបត្យាប័ន ឬ ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ប្រសិនបើរដ្ឋទទួលសំណើរមានភស្តុតាងគ្រប់គ្រាន់ជឿថាសំណើរសុំការធ្វើបត្យាប័នលើបទល្មើសដែលមានចែងក្នុងមាត្រា ២ ឬ ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ទាក់ទងនឹងបទល្មើសដែលបានកំណត់ដើម្បីគោលបំណងនៃការកាត់ទោស ឬ ការដាក់ទោសជនណាម្នាក់ដោយពូជសាសន៍របស់ជននោះ សាសនា ជនជាតិ ដើមកំណើត ឬ យោបល់ផ្នែកនយោបាយ ឬ ការគោរពតាមសំណើរនោះនឹងបណ្តាលអោយមានការរើសអើងចំពោះជននោះដោយមូលហេតុផ្សេងៗ ។

មាត្រា ១៣

១. ជនណាដែលកំពុងជាប់ឃុំឃាំង ឬ កំពង់បំរើទោសក្នុងដែនដីរបស់ភាគីរដ្ឋមួយ ហើយដែត្រូវបានស្នើសុំដោយភាគីរដ្ឋមួយទៀតដើម្បីធ្វើការឆ្លើយបំភ្លឺផ្តល់ភស្តុតាង ការចង្អុលបង្ហាញ ឬ បើពុំនោះទេផ្តល់ជំនួយក្នុងការទទួលបានភស្តុតាងសំរាប់ការស៊ើបអង្កេត ឬ ការកាត់ទោសចំពោះបទល្មើសតាមអនុសញ្ញានេះអាចត្រូវផ្ទេរប្រសិនបើត្រូវនឹងលក្ខណ្ឌដូចខាងក្រោម :

(ក) ជននោះផ្តល់ការឯកភាពរបស់ខ្លួន និង

(ខ) អាជ្ញាធរមិមានសមត្ថកិច្ចនៃរដ្ឋទាំងពីរឯកភាពអាស្រ័យតាមលក្ខណ្ឌដែលរដ្ឋទាំងនោះយល់ថាសមស្រប ។

២. ដើម្បីគោលបំណងនៃមាត្រានេះ:

(ក) រដ្ឋដែលជននេះត្រូវផ្ទេរទៅត្រូវមានអំណាច និង កាតព្វកិច្ចដើម្បីរក្សាជននេះក្នុងការឃុំឃាំង លើកលែងតែមានការស្នើសុំ ឬ ការអនុញ្ញាតិដោយរដ្ឋដែលផ្ទេរជននោះ ។

(ខ) រដ្ឋដែលជននោះផ្ទេរទៅត្រូវបអនុវត្តដោយមិនបង្អង់នូវកាតព្វកិច្ចរបស់ខ្លួនដើម្បីបញ្ជូនត្រឡប់ជននោះទៅក្រោមការឃុំឃាំងរបស់រដ្ឋដែលជននោះបានផ្ទេរមកដូចបានឯកភាពគ្នាជាមុន ឬ បើពុំនោះទេ បានឯកភាពដោយអាជ្ញាធរមិមានសមត្ថកិច្ចរបស់រដ្ឋទាំងពីរ ។

(គ) រដ្ឋដែលត្រូវបញ្ជូនជនផ្ទេរនោះទៅមិនត្រូវតំរូវអោយរដ្ឋផ្ទេរចាប់ផ្តើមដំណើរការធ្វើបត្យាប័នសំរាប់អោយជននោះត្រឡប់មកវិញនោះទេ ។

(ឃ) ជនដែលបានផ្ទេរត្រូវបានទទួលនូវការរាប់បញ្ចូលការបំរើទោសរួចហើយក្នុងរដ្ឋដែលផ្ទេរជននោះ និង រដ្ឋដែលទទួលខ្លួន ។

៣. លើលែងតែភាគីរដ្ឋដែលបានផ្ទេរជននោះមកស្រមតាមមាត្រានេះឯកភាពទោះជននោះជាសញ្ជាតិអ្វីក៏ដោយក៏មិនត្រូវទទួលការកាត់ទោស ឬ ឃុំឃាំង ឬ ត្រូវដាក់អោយស្ថិតនៅក្រោមបំរាមផ្សេងៗចំពោះសិទ្ធិសេរីភាពផ្ទាល់ខ្លួនក្នុងដែនដីរបស់រដ្ឋដែលជននោះត្រូវផ្ទេរទៅទាក់ទងនឹងអំពើ ឬ ការកាត់ទោសមុនពេលចេញដំណើររបស់ជននោះពីដែនដីដែលផ្ទេរជននោះ ។

## មាត្រា ១៤

ជនណាដែលជាប់ឃុំឃាំង ឬ ស្ថិតនៅក្រោមការចាត់វិធានការណាមួយ ឬ ការអនុវត្តនិតិវិធីណាមួយស្របតាមអនុសញ្ញានេះត្រូវទទួលបាននូវការធានា រួមទាំងការអនុវត្តនូវសិទ្ធិ និង ការធានាផ្សេងៗស្របតាមច្បាប់របស់រដ្ឋក្នុងដែនដីដែលជននោះវត្តមាន និង បញ្ញត្តិច្បាប់អន្តរជាតិផ្សេងៗទៀតស្តីអំពីសិទ្ធិមនុស្ស ។

## មាត្រា ១៥

ភាគីរដ្ឋត្រូវសហការណ៍ក្នុងការបង្ការទុបស្កាត់បទល្មើសដែលមានចែងក្នុងមាត្រា ២ ជាពិសេស:

(ក) ដោយការចាត់វិធានការដែលអាចអនុវត្តបាន ប្រសិនបើចាំបាច់រួមទាំងការកែប្រែច្បាប់ក្នុងស្រុករបស់ខ្លួនដើម្បីបង្កា និង ប្រឆាំងទល់នឹងការរៀបចំក្នុងដែនដីរបស់ខ្លួនសំរាប់ការប្រព្រឹត្តបទល្មើសទាំងនោះក្នុង និង ក្រៅដែនដីរបស់ខ្លួន រួមទាំងវិធានការហាមប្រាមក្នុងដែនដីរបស់ពួកគេនូវសកម្មភាពល្មើសច្បាប់របស់ជនទាំងនោះ ក្រុម និង អង្គការចាត់តាំងដែលជំរុញ ញុះញង់ រៀបចំ និង ផ្តល់ហិរញ្ញវត្ថុដោយចេតនា ឬ ពាក់ពន្ធ័ក្នុងការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ២ ។

(ខ) ដោយការផ្លាស់ប្តូរពត៌មានជាក់ច្បាស់ស្របតាមច្បាប់ជាតិរបស់ខ្លួន និង សំរបសំរួលវិធានការរដ្ឋបាល និង វិធានការផ្សេងៗទៀតដែលយល់ថាសមស្របដើម្បីបង្កទប់ស្កាត់ការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ២ ។

(គ) ក្នុងករណីសមស្រប តាមរយៈការស្រាវជ្រាវ និង ការរីកចំរើនទាក់ទងនឹងវិធីសាស្ត្រនៃការតាមដានជាតិផ្ទុះ និង សារធាតុដែលបង្កគ្រោះថ្នាក់ផ្សេងៗទៀតដែលបណ្តាលអោយគ្រោះថ្នាក់ដល់ជីវិត ឬ មានការប៉ះពាល់ដល់រាងកាយ ការប្រឹក្សា លើការរីកចំរើននូវបទដ្ឋាននៃការធ្វើគ្រឿងផ្ទុះដើម្បីកំណត់អំពីប្រភពក្នុងការស៊ើបអង្កេតក្រោយពេលផ្ទុះ ការផ្លាស់ប្តូរពត៌មានលើវិធានការបង្កាទុបស្កាត់ កិច្ចសហប្រតិបត្តិការណ៍ និង ការផ្ទេរបច្ចេកវិទ្យា ឧបករណ៍ និង សំភារៈដែលពាក់ពន្ធ័ ។

## មាត្រា ១៦

ដោយស្របតាមច្បាប់របស់ខ្លួន ឬ និតិវិធីដែលអាចអនុវត្តបានភាគីរដ្ឋដែលកាត់ទោសជនល្មើសត្រូវបញ្ជូនលទ្ធផលចុងក្រោយនៃនិតិវិធីទៅអគ្គលេខានៃអង្គការសហប្រជា ជាតិ ដែលជាអ្នកបញ្ជូនពត៌មានបន្តទៅភាគីរដ្ឋផ្សេងៗទៀត ។

## មាត្រា ១៧

ភាគីរដ្ឋត្រូវអនុវត្តការកិច្ចរបស់ខ្លួនតាមអនុសញ្ញានេះតាមវិធីសាស្ត្រដែលស្របទៅនឹងសមភាពនៃអធិបតេយ្យភាព និង បូរណភាពដែនដីរបស់រដ្ឋ និង ការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋផ្សេងៗទៀត ។

## មាត្រា ១៨

គ្មានអ្វីនៅក្នុងអនុសញ្ញានេះផ្តល់សិទ្ធិអោយភាគីរដ្ឋមួយអនុវត្តនូវដែនសមត្ថកិច្ចរបស់ខ្លួន និង តួនាទីដែលបានរក្សាសំរាប់អាជ្ញាធមរបស់ភាគីរដ្ឋផ្សេងដោយច្បាប់ក្នុងស្រុករបស់ខ្លួន ។

មាត្រា ១៩

១. គ្មានអ្វីនៅក្នុងអនុសញ្ញានេះត្រូវប៉ះពាល់ដល់សិទ្ធិផ្សេងៗ កាតព្វកិច្ច និង ការទទួលខុសត្រូវរបស់រដ្ឋ និង បុគ្គលក្រោមច្បាប់អន្តរជាតិ ជាពិសេសគោលបំណង និង គោលការណ៍របស់ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និង ច្បាប់មនុស្សធម៌អន្តរជាតិ ។

២. សកម្មភាពរបស់កងកំលាំងប្រដាប់អាវុធក្នុងពេលសង្គ្រាម ដូចដែលខ្លឹមសារបានកំណត់ក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ដែលគ្រប់គ្រងដោយច្បាប់នោះ តែមិនគ្រប់គ្រងដោយអនុសញ្ញានេះ និង សកម្មភាពដែលធ្វើឡើងដោយកងកំលាំងយោធារបស់រដ្ឋមួយក្នុងការអនុវត្តការកិច្ចជាផ្លូវការដែលមានចែងក្នុងគោលការផ្សេងៗទៀតនៃច្បាប់អន្តរជាតិ តែមិនស្ថិតក្រោមអនុសញ្ញានេះ ។

មាត្រា ២០

១. រាល់ជម្លោះរវាងភាគីរដ្ឋពីរ ឬ ច្រើនទាក់ទងនឹងការបកស្រាយ ឬ ការអនុវត្តអនុសញ្ញានេះដែលមិនអាច ដោះស្រាយបានតាមការចចាក្នុងពេលមួយសមស្រប នៅពេលមានសំណើរពីភាគីណាមួយត្រូវបញ្ជូនដើម្បីធ្វើ ការវិនិច្ឆ័យ ។ ប្រសិនបើក្នុងរយៈពេល ៦ ខែពីការកាលបរិច្ឆេតនៃការដាក់ស្នើនោះ ភាគីនៅតែមិនអាចឯក ភាពលើការរៀបចំការកាត់សេចក្តី ភាគីណាក៏ដោយនៃភាគីទាំងពីរអាចបញ្ជូនជម្លោះនោះទៅតុលាការយុត្តិ ធម៌អន្តរជាតិ ដោយការដាក់ពាក្យស្របតាមលក្ខខន្តិករបស់តុលាការ ។

២. នៅពេលចុះហត្ថលេខា ធ្វើសច្ចាប្បន ទទួលយក ឬ ការឯកភាពលើអនុសញ្ញានេះ ឬ ការឯកភាពដាក់បន្ថែមអោយប្រើ ភាគីរដ្ឋនីមួយៗប្រកាសថាខ្លួនមិនស្ថិតនៅក្រោមកថាខណ្ឌ ១នៃមាត្រនេះ ។ ភាគីរដ្ឋផ្សេងៗទៀតមិនស្ថិតនៅក្រោមកថាខណ្ឌ ១ នោះទេប្រសិនបើខ្លួនធ្វើការជំទាស់ ។

៣. រដ្ឋណាដែលធ្វើការជំទាស់ស្របតាមកថាខណ្ឌ ២ នៃមាត្រានេះអាចដកការជំទាស់របស់ខ្លួនវិញនៅពេលណាមួយក៏បានតាមរយៈការជូនដំណឹងដល់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

មាត្រា ២១

១. អនុសញ្ញានេះត្រូវបើកចំហរអោយចុះហត្ថលេខាដោយរដ្ឋទាំងអស់ចាប់ពីថ្ងៃទី ១២ ខែ មករា ១៩៩៨ រហូតដល់ ៣១ ធ្នូ ១៩៩៩ នៅទីស្នាក់ការរបស់អង្គការសហប្រជាជាតិនៅទីក្រុង ញូយ៉ក ។

២. អនុសញ្ញានេះត្រូវដាក់អោយធ្វើសច្ចាប្រ័ន ទទួលយក ឬ ឯកភាព ។ លិខិតតុបករណ៍នៃការធ្វើសច្ចាប្រ័ន ការទទួលយក ឬ ការឯកភាពត្រូវដាក់ដំកល់ជាមួយនឹងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

៣. អនុសញ្ញានេះត្រូវបើកចំហរអោយមានការដាក់បន្ថែមប្រើប្រាស់ដោយរដ្ឋ ។ លិខិតតុបករណ៍អំពីការដាក់បន្ថែមអោយប្រើត្រូវដាក់ដំកល់ជាមួយនឹងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

មាត្រា ២២

១. អនុសញ្ញានេះត្រូវចូលជាធរមានសាមសិបថ្ងៃបន្ទាប់ពីកាលបរិច្ឆេតនៃការដាក់ដំកល់លិខិតតុបករណ៍ទី ២២ នៃការធ្វើសច្ចាប្រ័ន ការទទួលយក ការឯកភាព ឬ ការដាក់អោយប្រើបន្ថែមជាមួយនឹងអគ្គលេខាធិការនៃ អង្គការសហប្រជាជាតិ ។

២. ចំពោះរដ្ឋនីមួយៗដែលធ្វើសច្ចាប្រ័ន ទទួលយក ឯកភាព ឬ ដាក់ប្រើប្រាស់បន្ថែមលើអនុសញ្ញានេះបន្ទាប់ពីដាក់ដំកល់លិខិតតុបករណ៍ទី ២២ នៃការធ្វើសច្ចាប្រ័ន ការទទួលយក ការឯកភាព ឬ ការដាក់អោយប្រើបន្ថែម អនុសញ្ញាត្រូវចូលជាធរមានសាមសិបថ្ងៃបន្ទាប់ពីការដាក់ដំកល់ដោយរដ្ឋនោះនូវលិខិតតុបករណ៍នៃការធ្វើសច្ចាប្រ័ន ការទទួលយក ការឯកភាព ឬ ការដាក់ប្រើប្រាស់បន្ថែម ។

មាត្រា ២៣

១. ភាគីណាក៏ដោយអាចជំទាស់នឹងអនុសញ្ញានេះដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គលេខានៃ អង្គការសហប្រជាជាតិ ។

២. ការប្តឹងជំទាស់ត្រូវចាត់ទុកថាបានការបន្ទាប់ពីរយៈពេលមួយឆ្នាំក្រោយពីអគ្គលេខាធិការនៃអង្គការសហប្រជាជាតិបានទទួលការជំទាស់នោះ ។

### មាត្រា ២៤

ទំរង់ដើមនៃអនុសញ្ញានេះជាភាសា អារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និង អេស្ប៉ាញមានតំលៃស្មើគ្នាត្រូវដាក់ដំកល់នៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិដែលត្រូវបញ្ជូនឯកសារចំលងទៅអោយរដ្ឋទាំងអស់ ។

ជាសក្ខីភាពនៃអនុសញ្ញានេះ តំណាងពេញសិទ្ធិដែលបានទទួលការចាត់តាំងពីរដ្ឋាភិបាលរបស់ខ្លួន បានចុះហត្ថលេខាលើអនុសញ្ញានេះ ហើយបានដាក់ចំហរដើម្បីចុះហត្ថលេខានៅទីស្នាក់ការរបស់អង្គការសហប្រជាជាតិ នៅទីក្រុង ញូយកចាប់តាំងពីថ្ងៃទី ១២ ខែ មករា ១៩៩៨ នេះតទៅ ។